**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១១៣ ព.ណ.ន.ល.ស.ប្រក

# ប្រកាស
## ស្តីពី
## ការកំណត់នីតិវិធីសម្រាប់ផ្តល់ការអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅក្រៅប្រទេស

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងលិខិតលេខ៩៨ សជណ.ពហ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១.-**

ត្រូវបានកំណត់នីតិវិធីសម្រាប់ផ្តល់ការអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅប្រទេសដៃគូពាណិជ្ជកម្មរបស់កម្ពុជា ក្នុងគោលបំណងជំរុញការធ្វើពាណិជ្ជកម្ម និងផ្សព្វផ្សាយ ផលិតផល វប្បធម៌ ទេសចរណ៍ និងគោលនយោបាយពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

នីតិវិធីសម្រាប់ផ្តល់ការអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា មានដូចខាងក្រោម៖

**១. លក្ខណៈសម្បត្តិរបស់បុគ្គលដាក់ពាក្យសុំបង្កើតមជ្ឈមណ្ឌល**

បុគ្គលដែលមានបំណងចង់បង្កើត **មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស** ចាំបាច់ត្រូវមានលក្ខណៈសម្បត្តិ ដូចខាងក្រោម៖



ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

- ជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា និងកំពុងប្រតិបត្តិការអាជីវកម្មជាប្រក្រតី ដែលមានទីតាំងអាសយដ្ឋានច្បាស់លាស់ ព្រមទាំងមិនស្ថិតក្នុងបញ្ជីជាប់ការអង្កេតរបស់ប្រទេសដើម ឬអាជ្ញាធរមានសមត្ថកិច្ច
- ជាម្ចាស់ទីតាំងផ្ទាល់ ឬមានកិច្ចសន្យាជួលទីតាំង ដោយបញ្ជាក់ពីអាសយដ្ឋានច្បាស់លាស់ និងទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាននៃប្រទេសម្ចាស់ផ្ទះ អំពីទីតាំង ទំហំ មិនប៉ះពាល់ចរាចរ ឬបរិស្ថាន និងមានស្តង់ដារបច្ចេកទេស ព្រមទាំងត្រូវទទួលបានការយល់ស្របពីក្រសួងពាណិជ្ជកម្មកម្ពុជាផងដែរ។

## ២. ពាក្យស្នើសុំ និងឯកសារភ្ជាប់

បុគ្គលស្នើសុំ ត្រូវដាក់ពាក្យស្នើសុំបង្កើត **មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា** មករដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា ដោយភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម៖

- ពាក្យស្នើសុំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស តាមគំរូភ្ជាប់ជាមួយប្រកាសនេះ
- កិច្ចសន្យាជួលទីតាំង និងគោលការណ៍អនុញ្ញាតផ្តល់ដោយអាជ្ញាធរមូលដ្ឋាននៃប្រទេសដែលសុំបើក និងដំណើរការមជ្ឈមណ្ឌលពាណិជ្ជកម្ម (ក្នុងករណីមិនទាន់មានលិខិតនេះអាចផ្តល់ពេលក្រោយទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងពាណិជ្ជកម្ម)
- វិញ្ញាបនបត្របញ្ជាក់ពីការចុះបញ្ជីជាសហគ្រាស ឬក្រុមហ៊ុននៅកម្ពុជា និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មនៅប្រទេសដើម ដែលបុគ្គលនោះកំពុងប្រតិបត្តិការអាជីវកម្ម ឬពាណិជ្ជកម្ម។

## ៣. ការចុះពិនិត្យ ការសម្រេចលើពាក្យស្នើសុំ សុពលភាពនៃលិខិតអនុញ្ញាត និងការដកហូតលិខិតអនុញ្ញាត

### ក. ការផ្តល់គោលការណ៍ជាមូលដ្ឋានដើម្បីចុះពិនិត្យ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នឹងចេញលិខិតផ្តល់គោលការណ៍ជាបណ្តោះអាសន្ន ជូនក្រុមហ៊ុនសម្រាប់យកទៅបំពេញបែបបទសុំបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា ពីអាជ្ញាធរនៅក្រៅប្រទេស ដែលលិខិតនេះមានសុពលភាពសម្រាប់រយៈពេល ៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃចុះហត្ថលេខា។ ក្នុងករណីដែលក្រុមហ៊ុនមិនអាចបំពេញបែបបទ និងនីតិវិធីបានចប់សព្វគ្រប់តាមលក្ខខណ្ឌតម្រូវរបស់អាជ្ញាធរមូលដ្ឋានក្នុងរយៈពេល ៦(ប្រាំមួយ)ខែនោះ លិខិតផ្តល់គោលការណ៍ចេញដោយក្រសួងពាណិជ្ជកម្ម ត្រូវចាត់ទុកជាមោឃៈ។

### ខ. ការចុះពិនិត្យទីតាំង

បុគ្គលស្នើសុំ ត្រូវដាក់លិខិតអញ្ជើញមកក្រសួងពាណិជ្ជកម្ម ដើម្បីចាត់មន្ត្រីជំនាញទៅសហការជាមួយទីប្រឹក្សា ឬអនុព័ន្ធពាណិជ្ជកម្មអមស្ថានឯកអគ្គរាជទូត ឬស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឱ្យចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដើម្បីពិនិត្យ និងសម្រេច។

មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម ត្រូវចុះបំពេញការងារនេះ យ៉ាងយូរបំផុតត្រឹមរយៈពេល ១០(ដប់)ថ្ងៃធ្វើការ ឬរាយការណ៍ជូនរដ្ឋមន្ត្រីពាណិជ្ជកម្មវិញ ក្នុងករណីមិនអាចចុះទៅពិនិត្យបាន។

មន្ត្រីជំនាញត្រូវរាយការណ៍អំពីលទ្ធផលចុះត្រួតពិនិត្យ ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម យ៉ាងយូរបំផុត ០៥(ប្រាំ)ថ្ងៃធ្វើការ បន្ទាប់ពីបានចុះពិនិត្យ។

### គ. ការសម្រេច និងផ្តល់លិខិតអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា

បន្ទាប់ពីទទួលរបាយការណ៍អំពីលទ្ធផលនៃការចុះពិនិត្យរបស់មន្ត្រីជំនាញ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មនឹងធ្វើការសម្រេចលើសំណើឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សម្រេចផ្តល់លិខិតអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម បុគ្គលស្នើសុំត្រូវចុះកិច្ចសន្យាជាមួយក្រសួងពាណិជ្ជកម្ម តាមគំរូភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីធានាបាននូវគោល

បំណងជំរុញការធ្វើពាណិជ្ជកម្ម និងផ្សព្វផ្សាយផលិតផល វប្បធម៌ ទេសចរណ៍ និងគោលនយោបាយពាណិជ្ជកម្មកម្ពុជានៅក្នុងប្រទេសដែលបានបង្កើតមជ្ឈមណ្ឌលនោះ ។

ទីប្រឹក្សា ឬអនុព័ន្ធពាណិជ្ជកម្មប្រចាំនៅក្រៅប្រទេស មានភារកិច្ចពិនិត្យតាមដាននូវការអនុវត្តសេចក្ដីសម្រេចរបស់ក្រសួងពាណិជ្ជកម្ម និងសកម្មភាពនានារបស់មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជាឲ្យស្របតាមកិច្ចសន្យា និងមានសមត្ថកិច្ចតាមច្បាប់ប្រគល់ជូន ក្នុងការបញ្ជាក់ពីយថាភូតភាពនៃលិខិតអនុញ្ញាតដែលចេញដោយក្រសួងពាណិជ្ជកម្ម។

**ឃ. សុពលភាពនៃលិខិតអនុញ្ញាត និងការសុំបន្តសុពលភាពលិខិតអនុញ្ញាត**

លិខិតអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស ចេញដោយក្រសួងពាណិជ្ជកម្ម មានសុពលភាពត្រឹមរយៈពេល ៣(បី)ឆ្នាំ ហើយអាចសុំបន្តសុពលភាពរយៈពេល ៣(បី)ឆ្នាំបន្ថែមទៀត តាមការចាំបាច់។

ដើម្បីធានាដល់កិច្ចដំណើរការនៃមជ្ឈមណ្ឌលពាណិជ្ជកម្មនោះ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពមកក្រសួងពាណិជ្ជកម្មរយៈពេល ៣(បី)ខែ មុនកាលបរិច្ឆេទអស់សុពលភាពនៃលិខិតអនុញ្ញាត។

**ង. ការដកហូតលិខិតអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្ម នឹងអនុវត្តវិធានការមួយចំនួន ដូចជា ណែនាំ ឬព្រមាន ឬដកហូតលិខិតអនុញ្ញាតឱ្យបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជាប្រចាំនៅក្រៅប្រទេស ព្រមទាំងធ្វើលិខិតជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសនោះ ក្នុងករណីម្ចាស់មជ្ឈមណ្ឌលមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា ឬបដិសេធការណែនាំអំពីលក្ខខណ្ឌ និងនីតិវិធីកំណត់ដោយច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

ម្ចាស់មជ្ឈមណ្ឌល និងមន្ត្រីរបស់ក្រសួងពាណិជ្ជកម្មត្រូវមានកាតព្វកិច្ច និងកិច្ចសម្របសម្រួល ដូចខាងក្រោម៖

**១. កាតព្វកិច្ចរបស់ម្ចាស់មជ្ឈមណ្ឌល**

ម្ចាស់មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស មានកាតព្វកិច្ច ដូចខាងក្រោម៖

- ត្រូវទទួលរ៉ាប់រងរាល់ការចំណាយទាក់ទងនឹងការបង្កើត ការរៀបចំទីតាំង ការគ្រប់គ្រង និងប្រតិបត្តិការប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា
- ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ និងកាតព្វកិច្ចនៃប្រទេសម្ចាស់ផ្ទះ ចំពោះសកម្មភាពទាំងឡាយរបស់មជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស ដែលខ្លួនកំពុងប្រតិបត្តិការ និងគ្រប់គ្រង
- ត្រូវធានាថា មានទំនិញ វត្ថុអនុស្សាវរីយ៍ មានលក្ខណៈវប្បធម៌ខ្មែរ ដែលផលិតនៅកម្ពុជា យ៉ាងតិច ៦០% ក្នុងចំណោមទំនិញដែលត្រូវបានដាក់តាំងបង្ហាញ និងដាក់លក់នៅក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជា
- ត្រូវរៀបចំរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួន ផ្ញើមកក្រសួងពាណិជ្ជកម្មកម្ពុជារៀងរាល់ ០៦ (ប្រាំមួយ) ខែម្ដង ឬតាមការចាំបាច់ តាមសំណូមពររបស់ក្រសួងពាណិជ្ជកម្មកម្ពុជា។

**២. កិច្ចសម្របសម្រួលរបស់ក្រសួងពាណិជ្ជកម្ម**

ក្រសួងពាណិជ្ជកម្ម ត្រូវផ្ដល់ការប្រឹក្សាផ្នែកបច្ចេកទេស ច្បាប់ និងជួយសម្របសម្រួលដល់ការប្រមូលផលិតផលខ្មែរ និងឯកសារផ្សព្វផ្សាយនានា ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម វិនិយោគ វប្បធម៌ និងទេសចរណ៍ ដើម្បីយកទៅដាក់តាំងបង្ហាញ និងផ្សព្វផ្សាយជាអចិន្ត្រៃយ៍នៅក្នុងមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស។

**ប្រការ៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥ ._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ទីប្រឹក្សា និងអនុព័ន្ធពាណិជ្ជកម្មប្រចាំនៅក្រៅប្រទេស និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំនៅក្រៅប្រទេស
- ស្ថានអគ្គរាជទូតកម្ពុជាប្រចាំនៅក្រៅប្រទេស
- ដូចប្រការ៥ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ